

# មុខតំណែងចុងភៅ

## Futures Factory សូមជម្រាបសួរ

តើអ្នកចូលចិត្តចំអិនម្ហូបដ៏ឆ្ងាញ់បែបខ្មែរ និង អាស៊ីដែរឬទេ?
តើអ្នកចង់ក្លាយជាផ្នែកមួយនៃគម្រោងច្នៃប្រឌិតថ្មី ដែលមានទីតាំងស្ថិតនៅកណ្តាលរាជធានីភ្នំពេញដែរឬទេ?

ប្រសិនបើអ្នកឆ្លើយ "ចាសឬបាទ" អ្នកប្រហែលជាបុគ្គលដែលយើងកំពុងស្វែងរក។
តើចំនុចខាងក្រោមនេះ? គិតថាត្រូវនឹងអ្នកដែរឬទេ?

- អ្នកមានជំនាញក្នុងការចំអិន និងច្នៃប្រឌិតម្ហូបផ្សេងៗ
- អ្នកយល់ដឹងអំពីស្តង់ដារអនាម័យ និងសុវត្ថិភាពចំណីអាហារ
- អ្នកចូលចិត្តបង្ហាត់យុវវ័យនូវជំនាញទាំងអស់ដែលត្រូវការសម្រាប់ចម្អិនម្ហូប
- អ្នកគឺជាបុគ្គលដែលមានទំនាក់ទំនងល្អក្នុងក្រុម នឹងជាមួយអ្នកដទៃ
- អ្នកចូលចិត្តរៀបចំមុខម្ហូបបែបសាមញ្ញ

យើងកំពុងចាប់ផ្តើមនូវគំនិតផ្តួចផ្តើមថ្មីមួយ ដើម្បីផ្តល់នូវមុខម្ហូបដ៏ឆ្ងាញ់ លើទីតាំងដ៏ស្រស់ស្អាតរបស់យើងនៅរាជធានីភ្នំពេញ។ ខណៈពេលដែលអ្នកកំពុងចំអិនម្ហូបឲ្យអតិថិជនរបស់យើងញ៉ាំដោយរីករាយ យុវវ័យនឹងរៀនពីអ្នក ហើយអ្នកនឹងក្លាយជាគ្រូចុងភៅ! គ្រូចុងភៅម្នាក់គឺមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះពួកគេជួយសិស្សរបស់ពួកគេឲ្យបញ្ចប់វគ្គរៀនធ្វើម្ហូបហើយបន្ទាប់មករកការងារធ្វើ!

យើងសង្ឃឹមថា អ្នកក៏រីករាយផងដែរដោយនឹងទទួលបាននូវជំនាញថ្មីៗ! អ្នកនឹងមានឱកាសធ្វើការ និងទទួលការបណ្តុះបណ្តាលពីក្រុមជំនាញអន្តរជាតិផ្នែកបដិសណ្ឋារកិច្ចរបស់យើង។ ដោយសារគម្រោងនេះជាផ្នែកមួយរបស់អង្គការមិត្តសំឡាញ់ អ្នកក៏នឹងទទួលបានការគាំទ្រពីក្រុមបុគ្គលិកសង្គម គ្រូបង្រៀន អ្នកជំនួញនិងអ្នកផ្សេងជាច្រើនទៀត។

តើអ្នកចាប់អារម្មណ៍ទេ? សូមផ្ញើប្រវត្តិរូបរបស់អ្នកឥឡូវនេះតាមរយៈអ៊ីម៉ែលៈ
hr@mithsamlanh.org ហើយយើងនឹងពិភាក្សាគ្នាបន្ថែមទៀត។
បេក្ខជនទាំងអស់នឹងត្រូវពិនិត្យប្រវត្តិរូបស្របតាមគោលការណ៍ការពារកុមាររបស់យើងChild/Bene ficiary Protection Policy and PSEA Policy

**លេខទូរស័ព្ទ** 096 809 3784 / 023 220 596

**អត្ថប្រយោជន៍**

- ផ្តល់កញ្ចប់អត្ថប្រយោជន៍ស្របតាមការងារ
- ផ្តល់អាហារ ១-២ ពេលក្នុងមួយថ្ងៃ
- ធ្វើការចំនួន៤៨ម៉ោងក្នុងមួយសប្តាហ៍
- ប្រាក់បៀវត្ស២៥០ដុល្លារឡើង (អាស្រ័យលើបទពិសោធន៍)